គណៈកម្មការប្រកួតបាល់ទាត់ជាតិកម្ពុជា

ការិយាល័យលេខ ០២
ផ្លូវលេខ ១៣៤
សង្កាត់វាលវង់ ខណ្ឌ ៧ មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក

ជាន់ទី១២ អគារ Exchange Square
ផ្លូវលេខ ១០៦ កែងផ្លូវលេខ ៦១
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

AIA.COM.KH

# សេចក្តីប្រកាសសារព័ត៌មានរួម

## AIA នាំគ្រូបង្វឹកអាជីពក្របខណ្ឌ English Premier League ដើម្បីបន្តបណ្តុះបណ្តាលគ្រូបង្វឹកក្នុងស្រុកៈ វគ្គទីពីរនៃការសហការណ៍រវាង AIA និងCNCC បានចាប់ផ្តើម

**រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩** – ជំហ៊ានទីពីរនៃ «វគ្គបណ្តុះបណ្តាលគ្រូបង្វឹក ដើម្បីអភិវឌ្ឍវិស័យបាល់ទាត់សម្រាប់សហគមន៍» ក្រោមការសហការណ៍រវាងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក ("អេ អាយ អេ ខេមបូឌា") និងគណៈកម្មការប្រកួតបាល់ទាត់ជាតិកម្ពុជា ("CNCC") បានចាប់ផ្តើមក្នុងថ្ងៃនេះ ជាមួយគ្រូបង្វឹកពីររូបលំដាប់ English Premier League ដែលបានផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្វឹកកម្ពុជាចំនួន ៥៦នាក់ដែលមកពីក្លិបនានាក្នុងក្របខណ្ឌកំពូលនៅកម្ពុជា Cambodian League។

កម្មវិធីនេះបានផ្តួចផ្តើមឡើងកាលពីខែកុម្ភៈក្នុងឆ្នាំនេះ ដោយមានការចូលរួមពីក្រុមគ្រូបង្វឹកនៃក្លិប Tottenham Hotspur Football Club ("Spurs") នៅក្នុងក្របខណ្ឌ English Premier League។ កម្មវិធីនេះ ផ្តោតសំខាន់លើការអភិវឌ្ឍវិស័យបាល់ទាត់កម្ពុជាក្នុងកម្រិតមូលដ្ឋាន ស្របពេលនឹងការជួយឲ្យសហគមន៍ទទួលបានសុខភាព និងជីវិតកាន់តែប្រសើរ។

នេះគឺជាវគ្គទីពីរនៃគម្រោងផ្តួចផ្តើមដែលមានបួនវគ្គ ហើយត្រូវបានធ្វើឡើងនៅសាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ ដែលផ្តោតលើការបង្កើតបរិយាកាសបង្ហាត់បង្រៀន និងការរៀបចំផែនការសកម្មភាពបណ្តុះបណ្តាលដែលល្អបំផុតសម្រាប់ក្មេងៗ។ គ្រូបង្វឹកទាំងពីររូបរបស់ Spurs គឺលោក Anton Blackwood និងលោក Aaron Arthur បានចំណាយពេលពេញមួយព្រឹកនេះក្នុងការផ្តល់ជូននូវបទពិសោធន៍ និងផ្ទេរចំណេះជំនាញដល់អ្នកចូលរួមទាំងអស់ ដែលរួមមានទ្រឹស្តីទាំងនៅក្នុងថ្នាក់រៀន និងការអនុវត្តជាក់ស្តែងក្នុងតារាងបាល់ទាត់ផ្ទាល់។

លោក Anton Blackwood បានលើកឡើងថា «ចំនុចសំខាន់នៃវគ្គទីពីរនៃកម្មវិធីនេះ គឺផ្តល់ឲ្យគ្រូបង្វឹកកម្ពុជានូវជំនាញ និងវិធីសាស្ត្រកម្រិតពិភពលោក ដែលយើងបានកសាងឡើងនៅក្នុងក្លិប Spurs ដើម្បីជួយឲ្យគ្រូបង្វឹកនៅទីនេះ អាចបង្កើតបរិយាកាសហ្វឹកហាត់ល្អបំផុតសម្រាប់ក្រុមយុវជន រួមជាមួយនឹងអត្ថប្រយោជន៍ច្រើនទៀតពីវគ្គបណ្តុះបណ្តាលនីមួយៗ។ ដោយឃើញពីកម្រិតទទួលយកខ្ពស់លើការហ្វឹកហាត់កន្លងមក យើងទុកចិត្តថាគ្រូបង្វឹកម្នាក់ៗកំពុងរីករាយនឹងកម្មវិធីនេះ ហើយក៏ស្វាគមន៍ទទួលយកចំណេះដឹងជាច្រើនដែលយើងកំពុងចែករំលែកផងដែរ»។

អេ អាយ អេ ខេមបូឌា អាចនាំគ្រូបង្វឹកទាំងពីររូបមកកាន់ប្រទេសកម្ពុជាដោយសារតែខ្លួនជាដៃគូផ្លូវការរបស់ក្លិប Spurs។ ជាផ្នែកមួយនៃការចាប់ដៃគូនេះ Spurs បានដាក់មូលដ្ឋានគ្រូបង្វឹកសម្រាប់ការអភិវឌ្ឍបាល់ទាត់សាកលពីរនាក់នៅទ្វីបអាស៊ី ដើម្បីគាំទ្រដល់ AIA ក្នុងការជួយកុមារា កុមារីទាំងឡាយបណ្តុះចំណាប់អារម្មណ៍របស់ពួកគេនៅលើវិស័យបាល់ទាត់ និងជួយឲ្យពួកគេយល់ដឹងអំពីអត្ថប្រយោជន៍នៃការលេងកីឡា។

លោកស្រី Pauline Teoh ថ្នាក់ដឹកនាំ អេ អាយ អេ ខេមបូឌា បានមានប្រសាសន៍ថា «ការជួយសហគមន៍ឲ្យរស់នៅមានសុខភាពល្អ និងជីវិតកាន់តែពេញលេញ គឺជាផ្នែកសំខាន់នៃការងាររបស់យើងនៅ អេ អាយ អេ ហើយយើងយកចិត្តទុកដាក់យ៉ាងខ្លាំងនៅលើចំនុចនេះ។ ដូច្នេះយើងពិតជាមានសេចក្តីសោមនស្សរីករាយជាខ្លាំង ដែលឃើញដៃគូរបស់យើងផ្តល់ជាអត្ថប្រយោជន៍ដល់ស្ថាប័នក្នុងស្រុកដូចជា CNCC និងក្លិបក្នុងក្របខណ្ឌ Cambodian League។ យើងសង្ឃឹមថាកម្មវិធីនេះ នឹងផ្តល់ផលវិជ្ជមានយ៉ាងខ្លាំងទៅលើការហ្វឹកហាត់កីឡាបាល់ទាត់ថ្នាក់មូលដ្ឋាននៅកម្ពុជា ព្រមទាំងអាចទាក់ទាញការចូលរួមពីកុមារា កុមារីតូចៗកាន់តែច្រើន ដើម្បីទទួលបានអត្ថប្រយោជន៍ពីការលេងកីឡាផងដែរ»។

កម្មវិធីនេះ រួមបញ្ចូលពីរវគ្គបន្ថែមទៀតដែលនឹងប្រព្រឹត្តទៅនៅឆ្នាំនេះ។ ហើយវគ្គបន្ទាប់ នឹងផ្តោតលើការអភិវឌ្ឍវិធីសាស្ត្របណ្តុះបណ្តាលពិស្តារលើការរៀបចំផែនការវគ្គបណ្តុះបណ្តាលរយៈពេលប្រាំមួយសប្តាហ៍។ វគ្គចុងក្រោយនឹងផ្តោតទៅលើវិធីសាស្ត្រដែលគ្រូបង្វឹកអាចប្រើប្រាស់វិធីសាស្ត្រទាំងអស់ ដែលពួកគាត់ទទួលបានពីវគ្គបណ្តុះបណ្តាលទាំងមូល ដើម្បីអាចបង្កើតកម្មវិធីបណ្តុះបណ្តាលដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ និងពេញលេញ។

លោកគ្រូបង្វឹក................... ដែលមកពីក្លិបដែលចូលរួម បានមានប្រសាសន៍ថា «សម្រាប់ខ្ញុំផ្ទាល់ ខ្ញុំបានយល់ដឹងច្រើនណាស់ថ្ងៃនេះ។ នេះជាឱកាសពិសេសខ្លាំងណាស់ ដែលខ្ញុំបានចូលរួមវគ្គបណ្តុះបណ្តាលជាមួយគ្រូបង្វឹកលំដាប់ពិភពលោកដូចលោក Anton និង Aaron។ ខ្ញុំនឹងចូលរួមវគ្គបន្ទាប់ទៀត ដើម្បីអាចបង្កើនជំនាញបង្វឹករបស់ខ្ញុំបន្ថែមទៀត»។

**អំពី អេ អាយ អេ ខេមបូឌា**

អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក ("អេ អាយ អេ ខេមបូឌា") គឺជាបុត្រសម្ព័ន្ធ និងជាកម្មសិទ្ធិទាំងស្រុងរបស់ AIA Group Limited ("AIA") ដែលជាសម្ព័ន្ធក្រុមហ៊ុនធានារ៉ាប់រងជីវិតធំជាងគេបំផុតនៅលើពិភពលោកដោយយោងតាមទីផ្សារមូលធននីយកម្ម។

សម្ព័ន្ធ AIA មានវត្តមាននៅក្នុងទីផ្សារចំនួន១៨នៅអាស៊ីប៉ាស៊ីហ្វិក ដែលក្នុងនោះមានសាខា និងបុត្រសម្ព័ន្ធដែលជាកម្មសិទ្ធិទាំងស្រុង នៅហុងកុង ថៃ សិង្ហបុរី ម៉ាឡេស៊ី ចិន កូរ៉េ ហ្វីលីពីន អូស្ត្រាលី ឥណ្ឌូនេស៊ី តៃវ៉ាន់ វៀតណាម ណូវែលហ្សេឡង់ ម៉ាកាវ ប្រ៊ុយណេ កម្ពុជា ព្រមទាំងបុត្រសម្ព័ន្ធដែលជាកម្មសិទ្ធិ៩៧ភាគរយនៅស្រីលង្កា ក្រុមហ៊ុនសម្ព័ន្ធអាជីវកម្ម៤៩ភាគរយនៅឥណ្ឌូនេស៊ី និងការិយាល័យតំណាងនៅមីយ៉ាន់ម៉ា។ AIA គឺជាក្រុមហ៊ុននាំមុខទីផ្សារក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (លើកលែងជប៉ុន) ដោយយោងលើបុព្វលាភធានារ៉ាប់រងជីវិត និងជាក្រុមហ៊ុនឈានមុខគេនៅក្នុងទីផ្សារភាគច្រើនរបស់ខ្លួន។ AIA មានទ្រព្យសរុប២៣០ពាន់លានដុល្លាអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។ តាមរយៈបណ្តាញដ៏ទូលំទូលាយនៃភ្នាក់ងារ ដៃគូ និងធនធានមនុស្សនានាទូទាំងអាស៊ីប៉ាស៊ីហ្វិក AIA បម្រើម្ចាស់បណ្ណសន្យាធានារ៉ាប់រង ៣៣លានបណ្ណ និងសមាជិកទទួលអត្ថប្រយោជន៍ធានារ៉ាប់រងតាមក្រុមហ៊ុននានាច្រើនជាង១៦លាននាក់។

អេ អាយ អេ ខេមបូឌា ផ្តល់ជូននូវដំណោះស្រាយ និងសេវាកម្មធានារ៉ាប់រងជីវិតឈានមុខគេក្នុងទីផ្សារ ដើម្បីបំពេញតម្រូវការលើការការពារ និងការសន្សំរយៈពេលវែង របស់ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា។ អេ អាយ អេ ខេមបូឌា ប្តេជ្ញាចូលរួមលើកកំពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៃព្រះរាជាណាចក្រកម្ពុជាឲ្យបានយូរអង្វែង និងជួយឲ្យប្រជាជនខ្មែរទទួលបានសុខភាព និងជីវិតកាន់តែប្រសើរ។

**អំពី គណៈកម្មការប្រកួតបាល់ទាត់ជាតិកម្ពុជា**

គណៈកម្មការប្រកួតបាល់ទាត់ជាតិកម្ពុជា ("CNCC") គឺជាសេនាធិការនៃសហព័ន្ធកីឡាបាល់ទាត់កម្ពុជា ("FFC")។ នៅចុងឆ្នាំ ២០១៦ CNCC ត្រូវបានបង្កើតឡើងក្នុងគោលបំណងគ្រប់គ្រងការប្រកួតបាល់ទាត់ក្នុងស្រុក ដើម្បីបន្តអភិវឌ្ឍន៏ពានរង្វាន់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងមិត្តហ្វូន ខេមបូឌាន លីគ ដែលមានឯកឧត្តម ឌី វិជ្ជា ជាប្រធានគណៈកម្មការនាយក នៃគណៈកម្មការប្រកួតបាល់ទាត់ជាតិកម្ពុជា។ CNCC មានការិយាល័យចំនួន៤៖ ការិយាល័យបច្ចេកទេស និងរៀបចំការប្រកួត ការិយាល័យរដ្ឋបាល ការិយាល័យហិរញ្ញវត្ថុ ព្រមទាំងការិយាល័យទីផ្សារ និងការផ្សព្វផ្សាយ។ បច្ចុប្បន្ន CNCC កំពុងរៀបចំពានរង្វាន់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងមិត្តហ្វូន ខេមបូឌាន លីគ។

**អំពីក្លឹបបាល់ទាត់ Tottenham Hotspur**

ក្លិបបាល់ទាត់ Tottenham Hotspur ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៨៨២ ដែលក្លិបនេះផ្តោតសំខាន់ទៅលើបែបផែននៃការលេងបាល់ទាត់បែបកំសាន្ត និងបែបប្រយុទ្ធ។ ក្រុមបាល់ទាត់នេះ បានទទួលចំណាត់ថ្នាក់លេខ៤ នៅក្នុងក្របខណ្ឌ Premier League នៅក្នុងរដូវកាល ២០១៨/២០១៩ សម្រេចបាននូវការចូលរួមក្នុង UEFA Champions League ៤ឆ្នាំជាប់ៗគ្នា និងបានជាប់ជុំចុងក្រោយលើកដំបូងបង្អស់ក្នុងប្រវត្តិរបស់ខ្លួន ក្នុងឆ្នាំនេះផ្ទាល់។

ក្រុមបាល់ទាត់ Tottenham Hotspur ក៏មាន៖

- អ្នកគាំទ្រលើសពី ៤០០ លាននាក់ទូទាំងពិភពលោក ដោយមានមូលដ្ឋានគាំទ្រធំៗនៅទូទាំងចក្រភពអង់គ្លេស សហរដ្ឋអាមេរិក និងទ្វីបអាស៊ី
- ក្លិបអ្នកគាំទ្រច្រើនជាង ១៩០ នៅទូទាំងពិភពលោក ដែលរួមមានក្លិបគាំទ្រសកម្ម និងពេញលេញនៅកម្ពុជាផងដែរ
- មជ្ឈមណ្ឌលបណ្តុះបណ្តាលបែបទំនើបទាន់សម័យបំផុត ជាមួយនឹងកីឡដ្ឋានលំដាប់ថ្នាក់ពិភពលោកថ្មីដែលនឹងមានប្រតិបត្តិការក្នុងពេលឆាប់ៗនេះ នៅចំកណ្តាលបេះដូងនៃទីក្រុងឡុងដុងខាងជើង
- ការចាប់ដៃគូពាណិជ្ជកម្ម ជាមួយនឹងក្រុមហ៊ុនលំដាប់ពិភពលោក ដូចជាសម្ព័ន AIA Group Limited ("AIA") ដែលជាក្រុមហ៊ុនធានារ៉ាប់រងជីវិតឈានមុខគេនៅលើពិភពលោក និងក្រុមហ៊ុន Nike ដែលជាក្រុមហ៊ុនសម្លៀកបំពាក់ និងស្បែកជើងកីឡាឈានមុខគេផងដែរ។

**ទំនាក់ទំនងសារព័ត៌មាន**

ហាក់ បញ្ញារ័ត្ន
ប្រធានផ្នែកទំនាក់ទំនងសាធារណៈ
អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក
០១៦/០១៧ ៣៦៩ ១៥៥
Panharath.Hak@aia.com

ម៉ា ភារ៉ា
ប្រធានផ្នែកផ្សព្វផ្សាយព័ត៌មាន
គណៈកម្មការប្រកួតបាល់ទាត់ជាតិកម្ពុជា
០៧០ ៥០៥ ៧៧០
pheara.ma@gmail.com